# មាតិកា

ទំព័រ


២ តើអ្វីជាច្បាប់ ?

៣ ទំនៀមទម្លាប់ វប្បធម៌ និង ច្បាប់

៤ ប្រព័ន្ធតុលាការប្រទេសកម្ពុជា

៦ ការធ្វើការជាមួយកូនក្តី

៩ ការពង្រឹងការអនុវត្តន៍ច្បាប់

១០ ការរៀបចំផែនការយុទ្ធសាស្ត្រច្បាប់

១៣ ការបង្កើតតុលាការសាធារណមតិ

១៥ ក្រុមសីលធម៌

១៥ ការឃ្លាំមើលតុលាការ

១៧ សន្ទនានុក្រម និង ឯកសារយោង

១៨ គំរូបញ្ជីសំណួរ






**អ្នកនិពន្ធ**

លោក ខូលីន ប៊ុន និង កញ្ញា វីកធ័ររៀ អេយើ

Colin Bunn, Victoria Ayer

**អ្នកកែសម្រួល**

លោក ឃើត ម៉ាកឡៅដ៍, លោក នី កែវប៉ុញ្ញា, អ្នកស្រី ជា ចាន់ឌី, លោក រស់ សុដ្ឋា, លោក ប៉ុល ហំម, លោក យ៉ាប់ មេត្តា ផេក កម្ពុជា
កុយ នាម, មូលនិធិអាស៊ី

Kurt MacLeod, Ny KeoPonha, Chea Chandy, Ros Sotha, Pol Ham, Yoib Meta, **Pact Cambodia**
Koy Neam, **The Asia Foundation**

**អ្នកគាក់តែងរូបភាព**

លោក ខូលីន ប៊ុន

Colin Bunn

# សេចក្ដីផ្ដើម




អំណាចមួយក្នុងចំណោមអំណាចសំខាន់ៗបំផុតទាំងអស់ គឺជាលទ្ធផលជំនាញក្នុងការបង្កើត នឹង ពង្រឹងការអនុវត្តន៍ច្បាប់។ អ្នកកាន់អំណាចពិតជាមានឥទ្ធិពលយ៉ាងខ្លាំងទៅលើជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។ សៀវភៅទី៥នៃកម្រងអត្ថបទសម្រាប់អ្នកជំនាញតស៊ូមតិនេះមានគោលបំណងសិក្សាស្វែងយល់ថាតើត្រូវប្រើប្រាស់ប្រព័ន្ធច្បាប់យ៉ាងដូចម្ដេចដើម្បីកែលំអជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និង ដើម្បីលើកកម្ពស់ និង ជំរុញឱ្យសម្រេចបានគោលបំណងរួមនៃការតស៊ូមតិរបស់យើង។

# តើច្បាប់ជាអ្វី ?

ច្បាប់គឺជាវិធានមួយសម្រាប់កំណត់ការប្រព្រឹត្តិ ឬ ឥរិយាបថរបស់ប្រជាពលរដ្ឋ។ ច្បាប់ត្រូវបានបង្កើតឡើង និង អនុវត្តដោយរដ្ឋាភិបាលដើម្បីបំរើប្រយោជន៍របស់ប្រជាពលរដ្ឋ។ ច្បាប់ជួយប្រជាពលរដ្ឋឱ្យមានអន្តរកម្មរវាងគ្នានិងគ្នា ច្បាប់សម្រាប់កំណត់បទដ្ឋានដែលត្រូវប្រព្រឹត្ត ដោះស្រាយជម្លោះ និង ការពារប្រជាពលរដ្ឋឱ្យជៀសផុតពីការរំលោភបំពាន។ ច្បាប់ដែលល្អត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម :

**យុត្តិធម៌**

ច្បាប់ត្រូវតែបានបង្កើតឡើងស្របទៅតាមគោលការណ៍សិទ្ធិមនុស្ស និង រដ្ឋធម្មនុញ្ញ។

**សមធម៌**

ច្បាប់ត្រូវតែបានអនុវត្តដោយស្មើភាពគ្នាចំពោះមនុស្សគ្រប់រូប។

**មានលក្ខណៈជាសកល**

ច្បាប់ត្រូវតែអនុវត្តបាននៅគ្រប់ស្ថានភាពនៃឥរិយាបថប្រហាក់ប្រហែលគ្នាទាំងអស់។

**ច្បាស់លាស់**

ច្បាប់ត្រូវតែបានកំណត់យ៉ាងច្បាស់លាស់ និង មិនជំទាស់នឹងច្បាប់ផ្សេងទៀត។

**អាចដាក់ឱ្យអនុវត្តបាន**

ច្បាប់ត្រូវតែងាយយល់ និង អាចអនុវត្តបាន ដើម្បីឱ្យប្រជាពលរដ្ឋអាចប្រើប្រាស់សម្រាប់ការពារសិទ្ធិរបស់ខ្លួន។

តួនាទីនៃប្រព័ន្ធច្បាប់គឺដើម្បីកំណត់ថាតើច្បាប់ត្រូវបានគេរំលោភដែរឬទេ និង ប្រសិនបើច្បាប់ត្រូវបានគេរំលោភមែន ប្រព័ន្ធច្បាប់ជាអ្នកកំណត់ការដាក់ទណ្ឌកម្មយ៉ាងសមស្រប។ ការដាក់ទណ្ឌកម្មមានគោលបំណងសំខាន់២គឺ : ដើម្បីកែលំអឥរិយាបថខុសច្បាប់របស់មនុស្ស និង ដើម្បីទប់ស្កាត់មនុស្សកុំឱ្យប្រព្រឹត្តបទឧក្រិដ្ឋស្រដៀងគ្នា។ និយាយជារួម ការដាក់ទណ្ឌកម្មទៅលើអំពើឧក្រិដ្ឋ បានជុំរុញឱ្យមានស្មារតីយុត្តិធម៌ត្រឹមត្រូវ និង ស្ថេរភាពនៅក្នុងសង្គមទាំងមូល។

**កំណត់សម្គាល់ :**
រដ្ឋអាចធ្វើឱ្យមានយុត្តិធម៌ពីអំពើមិនស្របច្បាប់តាមរយៈការដាក់ពិន័យ ឬ ដាក់ពន្ធនាគារជនប្រព្រឹត្តបទល្មើស ហើយប្រជាពលរដ្ឋម្នាក់អាចប្ដឹងទាមទារជំងឺចិត្តជាសាច់ប្រាក់ពីជនណាម្នាក់បាន ប៉ុន្តែមិនអាចដាក់ពន្ធនាគារជននោះបានឡើយ។

តុលាការជាអ្នកស្វែងរក ឬ "ជាអ្នកកាត់ទោសដើម្បីស្វែងរក" យុត្តិធម៌។ នៅក្នុងប្រទេសកម្ពុជា ចៅក្រមជាអ្នកស៊ើបអង្កេត ពិនិត្យភស្តុតាង និង ជាអ្នកសម្រេចថាតើនរណាម្នាក់ត្រូវទទួលទណ្ឌកម្ម ឬ ត្រូវសងជំងឺចិត្ត។ ការសម្រេចរបស់តុលាការគឺជាគំរូមួយសម្រាប់ឱ្យអ្នកដទៃគោរព និង អនុវត្តច្បាប់។



**រដ្ឋាភិបាល**ជាអ្នកសរសេរច្បាប់ ដោយមានការចូលរួមយោបល់ពីសំណាក់ប្រជាពលរដ្ឋ




**នគរបាល**ស៊ើបអង្កេតបទល្មើស និង ពង្រឹងការអនុវត្តន៍ច្បាប់



**ប្រព័ន្ធតុលាការ**ជាអ្នកស្វែងរកយុត្តិធម៌

# ទំនៀមទម្លាប់ វប្បធម៌ និង ច្បាប់

ទំនៀមទម្លាប់គឺជាប្រពៃណី ជំនឿ និង ការអនុវត្តន៍ជាក់ស្តែងរបស់មនុស្សមួយក្រុម ។ តាមទំនៀមទម្លាប់ខ្មែរ មុននឹងចូលផ្ទះចាំបាច់ត្រូវដោះស្បែកជើង ។ វប្បធម៌មានន័យថាជាសាសនា ប្រវត្តិសាស្ត្រ សិល្បៈ តម្លៃ និង ចំណេះដឹងដែលកើតឡើងពីពូជសាសន៍ សាសនា ឬ ក្រុមនៃសង្គម ។ ការកសាងវត្តអារាម និង ការប្រតិបត្តិតាមព្រះពុទ្ធសាសនា គឺជាផ្នែកមួយនៃវប្បធម៌របស់ប្រជាពលរដ្ឋខ្មែរ ។ ដើម្បីងាយយល់ និង ងាយអនុវត្តតាមច្បាប់ ជារឿយៗត្រូវបានបង្កើតឡើងដោយផ្អែកលើទំនៀមទម្លាប់ និង វប្បធម៌ ។ តែនៅមានទំនៀមទម្លាប់មួយចំនួនដែលត្រូវបានចាត់ទុកថាខុសច្បាប់ទាំងស្រុង ដូចជាការយកចិត្តទុកដាក់ដោយលំអៀងទៅលើបុរស និង ស្ត្រី ។ល ។




ការរាប់អានបុគ្គល ឬ ក្រុមមនុស្សខុសៗគ្នា គឺត្រូវបានចាត់ទុកថាជា "ការរើសអើង" ។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាត្រង់មាត្រាទី៣១ បានចែងថា ការរើសអើង គឺជាអំពើខុសច្បាប់ ។ ជាឧទាហរណ៍ : ការផ្សាយពាណិជ្ជកម្មជ្រើសរើសបុគ្គលិកសម្រាប់តែបេក្ខជនជាបុរស គឺជាអំពើខុសច្បាប់ ពីព្រោះការធ្វើបែបនេះបានបង្ហាញឱ្យឃើញពីការរើសអើងទៅលើភេទ ។

# តើមេធាវីជាអ្វី ?




មេធាវីជាអ្នកដែលទទួលបានការបណ្តុះបណ្តាលពិសេសនូវជំនាញផ្នែកច្បាប់ និង ដំណើរការរបស់តុលាការ ។ មេធាវីអាចប្រើប្រាស់មធ្យោបាយជាច្រើន ដើម្បីធ្វើឱ្យយើងយល់ពីសិទ្ធិរបស់យើង និង ច្បាប់គ្រប់គ្រងសហគមន៍ ។ ឧទាហរណ៍ ប្រសិនបើយើងជាជនដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ជាជនរងគ្រោះនៃបទឧក្រិដ្ឋ ចង់ចាប់ផ្តើមមុខជំនួញថ្មីមួយ ឬ ចង់លែងលះគ្នា មេធាវីអាចពន្យល់អំពីសិទ្ធិរបស់យើង ធ្វើជាតំណាងយើងនៅក្នុងតុលាការ និង ប្រមូលទឡ្ហីករណ៍មុនការកាត់ក្តី ។ មេធាវីក៏ជាអ្នកធ្វើការតស៊ូមតិមួយផងដែរ ដោយត្រូវដើរតួនាទីជាអ្នកនិយាយជំនួសមុខឱ្យប្រជាពលរដ្ឋដែលមិនអាចនិយាយសម្រាប់ខ្លួនឯងបាន ។

# តើប្រកាសជាអ្វី ?

ច្បាប់គឺជាសេចក្តីថ្លែងការណ៍ទូទៅអំពីវិធាន និង គោលការណ៍ ។ ក្នុងប្រទេសកម្ពុជា នៅពេលដែលច្បាប់ត្រូវបានអនុម័តហើយនោះក្រសួងពាក់ព័ន្ធត្រូវសរសេរ**ប្រកាស**ដើម្បីបញ្ជាក់អំពីរបៀបនៃការធ្វើឱ្យមានប្រសិទ្ធភាពសម្រាប់ការអនុវត្តន៍ច្បាប់ឱ្យដល់ទីបំផុត ។ បន្ទាប់មកត្រូវផ្សព្វផ្សាយដល់គ្រប់សមាជិករដ្ឋាភិបាល មន្ត្រីប៉ូលីស មេឃុំ ចៅសង្កាត់ និង សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងត្រូវផ្សព្វផ្សាយជាសាធារណៈដល់ប្រជាពលរដ្ឋ ។

# ប្រព័ន្ធតុលាការប្រទេសកម្ពុជា

ប្រព័ន្ធតុលាការប្រទេសកម្ពុជាមានអំណាច និង សមត្ថកិច្ច (យុត្តាធិការ) ធ្វើសេចក្ដីសម្រេចដោយផ្អែកលើរដ្ឋធម្មនុញ្ញកម្ពុជា ព្រមទាំងច្បាប់ និង ប្រកាសនានាដែលបានដាក់ឱ្យប្រើប្រាស់ និង ដែលនៅមានប្រសិទ្ធភាពជាធរមាននៅឡើយ។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល (Arbitration Council) មានសិទ្ធិសម្រេចទាំងស្រុងលើជម្លោះការងាររវាងនិយោជក និង សហជីពកម្មករ។ បន្ថែមលើនេះទៅទៀត នៅមានស្ថាប័នអន្តរជាតិពីរផ្សេងទៀតដែលអាចមានឥទ្ធិពលដល់ប្រព័ន្ធតុលាការប្រទេសកម្ពុជា និង អាចដើរតួនាទីជាប្រយោជន៍សម្រាប់ប្រជាពលរដ្ឋកម្ពុជាបានគឺ ៖ តុលាការយុត្តិធម៌អន្តរជាតិ (តុលាការពិភពលោក) និង តុលាការឧក្រិដ្ឋកម្មអន្តរជាតិ។



## តុលាការយុត្តិធម៌អន្តរជាតិ

តុលាការយុត្តិធម៌អន្តរជាតិ (តុលាការពិភពលោក) ត្រូវបានបង្កើតឡើងដោយអង្គការសហប្រជាជាតិ ដែលមានមូលដ្ឋាននៅទីក្រុងហេក (Hague) ប្រទេសហូឡង់ (Netherlands) ដើម្បីដោះស្រាយជម្លោះដែលកើតឡើងរវាងប្រទេស២ ឬ ច្រើន។

## តុលាការឧក្រិដ្ឋកម្មអន្តរជាតិ

តុលាការឧក្រិដ្ឋកម្មអន្តរជាតិ ត្រូវបានបង្កើតឡើងដោយអង្គការសហប្រជាជាតិ ដែលមានមូលដ្ឋាននៅទីក្រុងហេក (Hague) ប្រទេសហូឡង់ (Netherlands) ដើម្បីដោះស្រាយបទឧក្រិដ្ឋកម្មនានារបស់ប្រទេសណាមួយដែលប្រព័ន្ធតុលាការរបស់រដ្ឋមិនអាចកាត់ក្តីបាន។ ឧក្រិដ្ឋកម្មមានផលប៉ះពាល់ទូទាំងសហគមន៍អន្តរជាតិ។

### ការតស៊ូមតិនៅកម្ពុជា

អស់រយៈពេលជាច្រើនខែក្រោយពីការចរចាបរាជ័យ ថៅកែសម្ព័ន្ធសណ្ឋាគាររ៉ាហ្វែល (Raffles Hotels) និង សហជីពកម្មករ បានសូមឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលជួយដោះស្រាយជម្លោះរបស់ពួកគេលើប្រាក់ធានានុគ្រោះ។ ក្រុមប្រឹក្សាបានសម្រេចថា សម្ព័ន្ធសណ្ឋាគាររ៉ាហ្វែលនេះបានបញ្ឈប់ការងារកម្មកររបស់ខ្លួនចំនួន៩៧នាក់ដោយខុសច្បាប់ ហើយតម្រូវឱ្យសម្ព័ន្ធសណ្ឋាគារនេះទទួលកម្មករទាំងនេះធ្វើការវិញជាធម្មតា ដោយត្រូវបើកប្រាក់ខែឱ្យពួកគេដែលពួកគេបាត់បង់តាំងពីពួកគេត្រូវបានបញ្ឈប់កាលពីខែមេសា ហើយត្រូវបញ្ឈប់នូវរាល់ការចរចាជាមួយសហជីពណាដែលមិនបានចុះឈ្មោះ ឬ ដែលមិនបានទទួលស្គាល់ដោយក្រសួងការងារ។

**http://www.arbitrationcouncil.org**

## ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាល មានមូលដ្ឋាននៅក្នុងទីក្រុងភ្នំពេញ ហើយត្រូវបានបង្កើតឡើងស្របទៅតាមច្បាប់ការងាររបស់ប្រទេសកម្ពុជា ដើម្បីដោះស្រាយជម្លោះការងាររវាងនិយោជក និងសហជីពកម្មករ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានសមាជិកមកពីបីភាគីដែលត្រូវបានស្នើឡើងដោយសហជីព សមាគមនិយោជក និង ក្រសួងទទួលបន្ទុកវិស័យការងារ។

## ក្រុមប្រឹក្សាធម្មនុញ្ញ

មុខងារដ៏សំខាន់របស់ក្រុមប្រឹក្សាធម្មនុញ្ញគឺកំណត់ធម្មនុញ្ញភាពនៃច្បាប់ និងមានសិទ្ធិពិនិត្យ និងសម្រេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភា។ ក្រុមប្រឹក្សាធម្មនុញ្ញមានសមាជិក៩រូប ដែលត្រូវបានជ្រើសរើសដោយព្រះមហាក្សត្រ រដ្ឋសភា និង ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

## ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានមុខងារធានាឱ្យប្រព័ន្ធតុលាការមានដំណើរការរលូន។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមានសមាជិក៩រូប គឺ ព្រះមហាក្សត្រ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ប្រធានតុលាការកំពូល អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ប្រធានសាលាឧទ្ធរណ៍ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និង ចៅក្រមចំនួន៣រូប (ដែលត្រូវបានជ្រើសរើសដោយចៅក្រមខ្លួនឯង)។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមានអំណាចក្នុងការលើកតម្កើង និង ដាក់ពិន័យចៅក្រម។

## តុលាការកំពូល

តុលាការកំពូល គឺជាតុលាការទទួលរឿងក្តីឧទ្ធរណ៍មួយដែលខ្ពស់បំផុតនៅក្នុងប្រទេស ហើយមានមូលដ្ឋាននៅក្នុងទីក្រុងភ្នំពេញ។ យុត្តាធិការរបស់តុលាការកំពូល គ្របដណ្តប់នៅលើបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជាទាំងមូល ហើយសេចក្តីសម្រេចរបស់តុលាការកំពូល គឺមានលក្ខណៈចាប់បង្ខំ។ នៅក្នុងតុលាការកំពូលមានផ្នែករដ្ឋប្បវេណី នៅពេលជំនុំជម្រះម្តងៗត្រូវមានចៅក្រម៥រូបទទួលបន្ទុកធ្វើសេចក្តីសម្រេចលើរឿងរ៉ាវរដ្ឋប្បវេណី ដូចជា ជម្លោះអាពាហ៍ពិពាហ៍ ជម្លោះគ្រួសារ ជម្លោះការងាររដ្ឋបាល ជម្លោះលើការងារ និង ជម្លោះពាណិជ្ជកម្ម។ ក្រៅពីនេះតុលាការកំពូលនៅមានផ្នែកព្រហ្មទណ្ឌ នៅពេលជំនុំជម្រះម្តងៗត្រូវមានចៅក្រម ចំនួន៥រូបទទួលបន្ទុកធ្វើសេចក្តីសម្រេចលើករណីព្រហ្មទណ្ឌ។ ប្រសិនបើតុលាការកំពូលទទួលបានពាក្យបណ្តឹងមួយពាក់ព័ន្ធទៅនឹងបញ្ហារដ្ឋធម្មនុញ្ញ តុលាការកំពូលនឹងសូមឱ្យក្រុមប្រឹក្សាធម្មនុញ្ញជាអ្នកធ្វើសេចក្តីសម្រេច។

## សាលាឧទ្ធរណ៍

សាលាឧទ្ធរណ៍ មានមូលដ្ឋាននៅក្នុងទីក្រុងភ្នំពេញ ហើយជាអ្នកទទួលបណ្តឹងឧទ្ធរណ៍ពីតុលាការយោធា តុលាការខេត្ត និង តុលាការក្រុងនៅទូទាំងប្រទេស។ សាលាឧទ្ធរណ៍មានចៅក្រមចំនួន៧រូប ហើយពេលជំនុំជម្រះម្តងៗត្រូវមានចៅក្រម៣រូប ហៅថា គណៈវិនិច្ឆ័យ គឺជាអ្នកធ្វើសេចក្តីសម្រេចលើករណីនីមួយៗ។ ប្រសិនបើភាគីណាមួយយល់ថាក្តីរបស់ខ្លួនត្រូវបានតុលាការជាន់ទាបណាមួយសម្រេចខុស គឺភាគីនោះអាចប្តឹងឧទ្ធរណ៍មកសាលាឧទ្ធរណ៍បាន។

## តុលាការខេត្ត

តុលាការខេត្ត មានមុខងារដោះស្រាយរាល់ជម្លោះទាំងឡាយដែលកើតមានឡើងនៅតាមខេត្តទូទាំងព្រះរាជាណាចក្រកម្ពុជា។ ខេត្តនីមួយៗមានតុលាការខេត្តមួយដែលមានទីតាំងនៅក្នុងទីរួមខេត្ត។ បច្ចុប្បន្នព្រះរាជាណាចក្រកម្ពុជាមានតុលាការខេត្តចំនួន១៩។

## តុលាការយោធា

តុលាការយោធា មានមុខងារដោះស្រាយជម្លោះបទល្មើសយោធាពាក់ព័ន្ធទៅនឹងវិន័យយោធា ឬ ការបំផ្លាញទ្រព្យសម្បត្តិយោធា តែករណីផ្សេងៗទៀតក្រៅពីនេះ នឹងត្រូវបានដោះស្រាយដោយតុលាការខេត្ត និង តុលាការក្រុង។ តុលាការយោធាគ្រប់គ្រងដោយក្រសួងការពារជាតិ។

## តុលាការក្រុង

តុលាការក្រុង មានមុខងារដោះស្រាយជម្លោះទាំងឡាយដែលកើតមាននៅក្នុងក្រុង។ តុលាការក្រុងមាននៅក្រុងភ្នំពេញ និង ក្រុងព្រះសីហនុ។

# ការធ្វើការជាមួយកូនក្តី

ក្រៅពីធ្វើការតស៊ូមតិដើម្បីទាមទារសិទ្ធិ មានអង្គការមិនមែនរដ្ឋាភិបាលជាច្រើនដែលផ្តល់ឱ្យអ្នកទទួលផលរបស់ខ្លួននូវសេវាកម្មចាំបាច់មួយចំនួនដូចជា ការថែទាំសុខភាព ម្ហូបអាហារ សន្តិសុខ ជម្រក និង ការបណ្តុះបណ្តាលវិជ្ជាជីវៈ ។ល។ តែទោះជាយ៉ាងណាក៏ដោយ នៅមានបញ្ហាមួយចំនួនរបស់ក្រុមគោលដៅដែលចាំបាច់ត្រូវតែធ្វើការដោះស្រាយតាមរយៈប្រព័ន្ធច្បាប់ ។ ក្នុងករណីដែលបុគ្គលម្នាក់ត្រូវបានគេបដិសេធមិនឱ្យការងារធ្វើ ពីព្រោះតែបុគ្គលនោះមានផ្ទុកមេរោគអេដស៍ ឬ ក្នុងករណីដែលដីធ្លីរបស់កសិករត្រូវបានគេរឹបអូសយកដោយខុសច្បាប់នោះ វិធានការមួយដ៏សមស្របបំផុត គឺត្រូវជួយជនរងគ្រោះដោយអំពើខាងលើតាមរយៈតុលាការ ។

### ១ ប៉ាន់ប្រមាណ និង ធ្វើការចាប់អារម្មណ៍នៅលើតម្រូវការបន្ទាន់របស់កូនក្តី

ផ្តល់សុវត្ថិភាព សន្តិសុខ ម្ហូបអាហារ និង ជម្រកដល់កូនក្តី និង គ្រួសារ ។ កូនក្តីមិនអាចឆ្លើយសំណួរដែលយើងសួរបានឡើយ បើសិនណាគាត់ឃ្លៀយ ហត់ ឃ្លាន ឬ ក៏ស្ថិតក្នុងស្ថានភាពមួយដែលត្រូវការការថែទាំផ្នែកពេទ្យ ។

### ២ ធ្វើសម្ភាសន៍

មុនពេលយើងចាប់ផ្តើមសម្ភាសន៍កូនក្តី យើងត្រូវបង្កើតឱ្យមានបរិយាកាសកក់ក្តៅ និង អាចជឿទុកចិត្តគ្នាបាន ។ នៅពេលណាដែលយើងយល់ឃើញថាកូនក្តីនោះកក់ក្តៅហើយ យើងត្រូវចាប់ផ្តើមជាមួយនឹងសំណួរដែលងាយៗ និង ទូទៅ មុនពេលបន្តទៅសំណួរផ្ទាល់ខ្លួន និង ជាក់លាក់ ។

### ៣ បំពេញទម្រង់ព័ត៌មានកូនក្តី

ប្រើបញ្ជីសំណួរស្តង់ដារដូចៗគ្នាសម្រាប់គ្រប់កូនក្តីទាំងអស់ ។ បញ្ជីសំណួរនេះគួរតែលំអិត និង ច្បាស់លាស់ និង មានព័ត៌មានដែលសំខាន់សម្រាប់ទាំងមេធាវី និង ការងារតស៊ូមតិផ្នែកច្បាប់របស់យើង ។

### ៤ កត់ត្រាលំអិតលើករណីនីមួយៗ

កត់ត្រានូវរាល់ការរំលោភបំពានដែលបានកើតមានឡើង ។ ត្រូវធ្វើការវិភាគទិន្នន័យដែលប្រមូលបានជាទៀងទាត់ដើម្បីកំណត់តម្រុយ ។ យើងក៏អាចបញ្ចូលគ្នានូវករណីស្រដៀងគ្នាជាច្រើន ដើម្បីទាញឱ្យឃើញនូវផលប៉ះពាល់កាន់តែច្បាស់ ។ យើងក៏ត្រូវធ្វើការប្រៀបធៀបទិន្នន័យ និង ស្ថិតិរបស់យើងជាមួយអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗទៀតដែរ ។

### ៥ ធ្វើការសម្រេចថាតើគួរប្តឹងករណីនេះទៅតុលាការដែរឬទេ?

ពិគ្រោះយោបល់ជាមួយមេធាវីដើម្បីចង់ដឹងថាតើករណីនេះមានការរំលោភច្បាប់ដែរឬទេ ។ តើការប្តឹងករណីនេះទៅតុលាការគឺជាជម្រើសមួយដ៏ល្អដើម្បីជួយកូនក្តីមែនទេ ? តើយើងអាចអះអាងប្រាប់កូនក្តីថានីតិវិធីនេះនឹងប្រព្រឹត្តិទៅដោយមនុស្សធម៌ និង ការគោរពគ្នាដែរឬទេ? តើការនាំកូនក្តីប្តឹងទៅតុលាការនឹងនាំមកនូវភាពតានតឹងដែរឬទេ ? ហើយតើយើងត្រូវធ្វើដូចម្តេច ដើម្បីជួយកូនក្តីដោះស្រាយបញ្ហាទាំងនោះ ?

## យើងមិនគួរដាក់ពាក្យបណ្តឹងស្របច្បាប់ណាមួយដោយមិនទាន់ទទួលបានការយល់ព្រមទាំងស្រុង និង យល់ដឹងច្បាស់ពីកូនក្តីនោះឡើយ

មានហេតុផលល្អៗជាច្រើនដែលកូនក្តី បានបដិសេធមិនព្រមដាក់ពាក្យបណ្តឹងទៅតុលាការ ។ ដូចនេះដើម្បីការពារសិទ្ធិរបស់កូនក្តី យើងមិនត្រូវរំលោភលើការទុកចិត្ត និង ការសម្ងាត់នៃបញ្ហារបស់ពួកគេឡើយ ដូចគ្នានេះដែរយើងក៏មិនអាចធ្វើការសម្រេចជំនួសពួកគេដោយគ្មានការព្រមព្រៀងពីពួកគេបានដែរ ។

ប្រសិនបើយើង និង កូនក្តីសម្រេចដូចគ្នាថានឹងដាក់ពាក្យបណ្តឹងទៅតុលាការ នោះយើងត្រូវធ្វើទំនាក់ទំនងជាមួយនឹងសេវាកម្មផ្នែកច្បាប់ដូចជា អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ឬ គម្រោងការពារយុត្តិធម៌សម្រាប់កុមារ បន្ទាប់មកត្រូវរៀបចំយុទ្ធសាស្ត្រច្បាប់ និង តាមដានពិនិត្យការវិវឌ្ឍន៍នៃពាក្យបណ្តឹង ។

### ការតស៊ូមតិនៅកម្ពុជា

អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ដែលហៅកាត់ថា (CDP) គឺជាអតីតគម្រោងមួយរបស់ក្រុមអ្នកច្បាប់ការពារសិទ្ធិមនុស្សអន្តរជាតិ ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៩៤ នៅក្នុងប្រទេសកម្ពុជា ។ ក្រៅពីការផ្តល់សេវាផ្នែកច្បាប់ដោយឥតគិតថ្លៃដល់ប្រជាពលរដ្ឋដែលក្រីក្រ និង ដែលងាយរងគ្រោះ អង្គការ CDP បានបង្កើតឡើងនូវគម្រោងតូចៗជាច្រើនទៀត ដើម្បីផ្សព្វផ្សាយការយល់ដឹងពីច្បាប់ ការតស៊ូមតិសម្រាប់នីតិកម្មមួយល្អជាងមុន និង ដើម្បីផ្តល់ការការពារជាពិសេសដល់ក្រុមប្រជាពលរដ្ឋដែលងាយរងគ្រោះបំផុត ។

**http://www.cdpcambodia.org**

# សម្ភាសន៍

សម្ភាសន៍គឺជាវិធីសាស្ត្រដ៏ល្អមួយក្នុងចំណោមវិធីសាស្ត្រល្អបំផុតទាំងឡាយដែលត្រូវបានប្រើប្រាស់សម្រាប់ប្រមូលព័ត៌មានដើម្បីធ្វើការសិក្សាស្វែងយល់ពីតម្រូវការរបស់កូនក្តី និង ដើម្បីជួយដោះស្រាយបញ្ហារបស់ពួកគេ។ ដំណើរការសម្ភាសន៍គឺពុំមែនជាឱកាសសម្រាប់តែការឆ្លងឆ្លើយប៉ុណ្ណោះទេ ប៉ុន្តែវាត្រូវបានធ្វើឡើងច្រើនដំណាក់កាលដើម្បីកសាងទំនុកចិត្តគ្នាទៅវិញទៅមក។ យើងត្រូវបញ្ជាក់ឱ្យបានច្បាស់ពីស្ថានភាពរបស់កូនក្តីដោយត្រូវប្រមូលគ្រប់ព័ត៌មានពាក់ព័ន្ធទាំងអស់ និង ត្រូវជួយកូនក្តីរបស់យើងឱ្យធ្វើការសម្រេចជ្រើសរើសវិធីសាស្ត្រមួយដ៏ល្អបំផុត ដើម្បីដំណើរការដោះស្រាយបញ្ហារបស់ពួកគេ។

បន្ទាប់ពីយើងប្រាកដថាកូនក្តីរបស់យើងមានសុវត្ថិភាព និង មានទំនុកចិត្តលើយើងហើយនោះ សូមឱ្យពួកគេចាប់ផ្តើមនិទានប្រាប់យើងនូវសាច់រឿងទាំងមូល ដោយមិនត្រូវលើកសំណួរ និង បង្កការរំខានអ្វីមួយដល់ពួកគេឡើយ។ ជារឿយៗ ពួកគេតែងតែមានការឈឺចាប់ និង ការក្តុកក្តួលក្នុងចិត្ត នៅពេលបកស្រាយសាច់រឿងទាំងមូលរបស់ពួកគេ។ ហេតុដូច្នេះ ជាការសំខាន់យើងត្រូវផ្តល់ឱ្យពួកគេនូវពេលវេលាគ្រប់គ្រាន់ និង ការយកចិត្តទុកដាក់តាមដានស្តាប់ និង ត្រូវគោរពនូវអ្វីដែលបានកើតឡើងចំពោះពួកគេ។ ប្រសិនបើដំណើរការសម្ភាសន៍នេះត្រូវបានអនុវត្តទៅបានល្អ យើងប្រាកដជាអាចបង្កើតឱ្យមាននូវទំនាក់ទំនងមួយដ៏ល្អជាមួយកូនក្តី ហើយយើងនឹងបានយល់នូវរូបភាពទូទៅនៃសាច់រឿងដែលពួកគេបានរៀបរាប់។ នៅពេលណាដែលកូនក្តីមានអារម្មណ៍កក់ក្តៅជាមួយយើងហើយនោះ យើងអាចចាប់ផ្តើមសួរសំណួរជាក់លាក់មួយចំនួន ដើម្បីបញ្ជាក់ឡើងវិញ។

មានសំណួរពីរប្រភេទដែលត្រូវបានប្រើប្រាស់សម្រាប់សម្ភាសន៍ គឺ សំណួរបើក និង សំណួរបិទ។ សំណួរបើកជាសំណួរមួយដែលមានលក្ខណៈទូលំទូលាយ និង ដែលផ្តល់លទ្ធភាពឱ្យកូនក្តីបកស្រាយសាច់រឿងរបស់ខ្លួនតាមរបៀបដែលពួកគេពេញចិត្ត។ សំណួរបើកគួរតែត្រូវបានប្រើនៅពេលចាប់ផ្តើមដំណើរការសម្ភាសន៍ ដើម្បីយល់ឱ្យបានច្បាស់ និង លំអិតជាមូលដ្ឋានពីសាច់រឿងរបស់ពួកគេ ជាមួយគ្នានេះដែរត្រូវព្យាយាមធ្វើឱ្យមានទំនាក់ទំនងកាន់តែស្និទ្ធស្នាល និង ទំនុកចិត្តជាមួយកូនក្តី។ ដោយឡែកសំណួរបិទ គឺជាប្រភេទសំណួរដែលកាន់តែជាក់លាក់ និង ជាទូទៅចម្លើយដែលត្រូវឆ្លើយគឺ "បាទ/ចាស៎" ឬ "ទេ"។ ដោយសារតែសំណួរបិទ ជាប្រភេទសំណួរដែលមានលក្ខណៈមិនអាចបត់បែនបាន និង មិនសូវជិតស្និទ្ធ យើងមិនគួរប្រើសំណួរប្រភេទនេះញឹកញាប់ពេកនោះទេ ហើយយើងគួរតែប្រើវាដរាបណាយើងជឿជាក់ថាកូនក្តីរបស់យើងមានការទុកចិត្ត និង ជិតស្និទ្ធជាមួយយើងបានល្អហើយ។




"សូមមេត្តាជួយរៀបរាប់ប្រាប់ខ្ញុំថាតើមានរឿងអ្វីខ្លះបានកើតឡើងក្នុងយប់នោះ ?"

"តើមាននរណាខ្លះពាក់ព័ន្ធក្នុងរឿងនោះដែរ ?"

"តើអ្នកមានអារម្មណ៍យ៉ាងដូចម្តេចឥឡូវនេះ ?"

"តើអ្នកនឹងត្រូវធ្វើយ៉ាងម៉េចតទៅទៀត ?"

"តើមានអ្នកដែលអាចជួយអ្នកបានដែរឬទេក្នុងគ្រាដ៏លំបាកបែបនេះ ?"

"តើអ្នកគិតថាហេតុអ្វីបានរឿងនោះវាកើតឡើង ?"

"តើអ្នកគិតយ៉ាងដូចម្តេចសម្រាប់ពេលខាងមុខ ?"




"តើរឿងនេះបានកើតឡើងនៅកន្លែងណា ?"

"តើអ្នកបានត្រឡប់មកផ្ទះដែរឬទេបន្ទាប់ពីឧប្បត្តិហេតុនោះកើតឡើង ?"

"តើមានអ្នកណាបានឃើញឧប្បត្តិហេតុនោះផ្ទាល់ភ្នែកដែរឬទេ ?"

"តើអ្នកស្គាល់អ្នកប្រព្រឹត្តនោះដែរឬទេ ?"

"តើអ្នកបានហូបបាយល្ងាចដែរឬទេ ?"

"តើអ្នកមានសំបុត្រអាពាហ៍ពិពាហ៍ (អេតាស៊ីវិល) ដែរឬទេ ?"

"តើឧប្បត្តិហេតុនោះបានកើតឡើងនៅម៉ោងប៉ុន្មាន ?"

# ទម្រង់ព័ត៌មានកូនក្តី

របៀបរបបក្នុងការធ្វើសម្ភាសន៍គឺតែងតែខុសគ្នា អាស្រ័យទៅតាមបទពិសោធន៍របស់អ្នកធ្វើសម្ភាសន៍ កូនក្តី និង កាលៈទេសៈនីមួយៗ។ តែទោះជាយ៉ាងណាក៏ដោយ សំណួរដែលត្រូវសួរកូនក្តីទាំងអស់គួរតែដូចគ្នា។ វិធីសាស្ត្រមួយដើម្បីធ្វើឱ្យដំណើរការសម្ភាសន៍មានលក្ខណៈជាស្តង់ដារ គឺត្រូវប្រើ "ទម្រង់ព័ត៌មានកូនក្តី"។ នៅក្នុងទម្រង់ព័ត៌មានកូនក្តីរួមមានសំណួរជាមូលដ្ឋាន និង សំណួរផ្នែកច្បាប់មួយចំនួនដែលត្រូវសួរនៅគ្រប់សម្ភាសន៍ទាំងអស់។ ចាំបាច់ត្រូវធ្វើការពិគ្រោះយោបល់ជាមួយមេធាវីនៅពេលរៀបចំបង្កើតទម្រង់ព័ត៌មានកូនក្តីប្រភេទនេះ ឬ អាចប្រើប្រាស់ទម្រង់ព័ត៌មានកូនក្តីគំរូដែលមានភ្ជាប់នៅផ្នែកខាងក្រោយនៃសៀវភៅនេះស្រាប់ក៏បាន។ ត្រូវធ្វើឱ្យប្រាកដថាសម្ភាសន៍ដោយប្រើទម្រង់ព័ត៌មានកូនក្តីនេះ នឹងត្រូវបានធ្វើឡើងដោយបុគ្គលិកដែលទទួលបានការបណ្តុះបណ្តាលយ៉ាងច្បាស់ពីរបៀបសម្ភាសន៍ និង របៀបប្រើប្រាស់ទម្រង់ព័ត៌មានកូនក្តី និង ជាអ្នកដែលចេះបត់បែនបានល្អក្នុងករណីដែលកូនក្តីមានភាពតានតឹងក្នុងការឆ្លើយតបសម្ភាសន៍។

ជាការសំខាន់ត្រូវបកស្រាយឱ្យបានច្បាស់ពី "ដំណើរការសម្ភាសន៍ និង បំពេញទម្រង់ព័ត៌មានកូនក្តី" ដល់កូនក្តីមុននឹងចាប់ផ្តើមសម្ភាសន៍ ហើយត្រូវពន្យល់ដល់ពួកគាត់ថាសម្ភាសន៍នេះអាចនឹងចំណាយពេលយូរ ប៉ុន្តែគោលបំណងសំខាន់គឺដើម្បីប្រមូលព័ត៌មាន។ ព័ត៌មាននេះនឹងផ្តល់លទ្ធភាពឱ្យយើងក្នុងការកំណត់នូវប្រភេទសេវារបស់យើងសម្រាប់ពួកគាត់ ទន្ទឹមនឹងនេះយើងត្រូវលើកទឹកចិត្តកូនក្តីឱ្យលើកជាសំណួរ ប្រសិនបើពួកគេមិនសូវយល់ច្បាស់ពីដំណើរការនេះ។ ទីបំផុតក្រោយពីប្រមូលព័ត៌មានបានហើយ យើងត្រូវរៀបចំទម្រង់ព័ត៌មានកូនក្តីដែលបានបំពេញ ដើម្បីឱ្យព័ត៌មានដែលបានប្រមូលទាំងនោះត្រឹមត្រូវតាមប្រភេទ និង លំដាប់នៃព័ត៌មាន ព្រមទាំងអាចរកវិញឃើញស្រួល។ ឧទាហរណ៍ ៖ យើងអាចដាក់រាល់ករណីពាក់ព័ន្ធនឹងអំពើហិង្សាតាមខេត្ត ឬ ទៅតាមអាយុរបស់ជនរងគ្រោះ។

ជាទូទៅ ការចងចាំរបស់មនុស្សនឹងរលុបបន្តិចម្តងៗ សាក្សីដែលឃើញផ្ទាល់ភ្នែកនឹងផ្លាស់ប្តូរកន្លែងរស់នៅពីកន្លែងមួយទៅកន្លែងមួយទៀត ហើយស្លាកស្នាមដែលបង្កនៅលើរាងកាយនឹងជាសះស្បើយបន្តិចម្តងៗទៅតាមពេលវេលា។ ដូច្នេះជាការសំខាន់ត្រូវកត់ត្រានូវរាល់ព័ត៌មាន និង ភស្តុតាងទាំងឡាយភ្លាមៗឱ្យបានលំអិត និង ច្បាស់លាស់ ដើម្បីកត់ត្រាទុកនូវរាល់ការឈឺចាប់ទាំងឡាយរបស់កូនក្តីក្នុងអំឡុងពេលនៃឧប្បត្តិហេតុ។




នៅខាងក្រោយនៃសៀវភៅតូចនេះ យើងមានភ្ជាប់មកជាមួយនូវបញ្ជីសំណួរគំរូមួយ។ លោកអ្នកអាចប្រើប្រាស់ ឬ កែសម្រួលបញ្ជីសំណួរនេះទៅតាមតម្រូវការសម្រាប់សម្ភាសន៍ជាមួយអតិថិជន របស់លោកអ្នក។

# ការពង្រឹងការអនុវត្តន៍ច្បាប់

ជួនកាលករណីកូនក្តីហាក់ដូចជាបានបង្ហាញយ៉ាងច្បាស់នូវភាពសមស្របសម្រាប់ដំណោះស្រាយផ្លូវច្បាប់។ តែទោះជាយ៉ាងណាក៏ដោយ នៅពេលដែលច្បាប់មួយទើបតែបានអនុម័ត ឬ ដែលមិនបានអនុវត្តត្រឹមត្រូវ ជាបឋមយើងត្រូវ "សាកល្បង" នូវប្រសិទ្ធភាពនៃប្រព័ន្ធច្បាប់នោះ។ ខាងក្រោមនេះជាវិធីសាស្ត្រពីរដែលយើងអាចប្រើប្រាស់ដើម្បីសាកល្បងនូវប្រសិទ្ធភាពនៃច្បាប់ស្តីពីការបង្ការ និង ការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជម្ងឺអេដស៍នៅក្នុងប្រទេសកម្ពុជា។

| | ករណីសាកល្បងទី ១ | ករណីសាកល្បងទី ២ |
|---|---|---|
| **សម្រេចថាតើឥរិយាបថអ្វីខ្លះដែលត្រូវផ្លាស់ប្តូរ ?** | យើងដឹងថាមានមន្ទីរពេទ្យ និង គ្លីនិកនៅតាមខេត្តមួយចំនួនបានបង្ហាញឱ្យដឹងលទ្ធផលមេរោគអេដស៍របស់ប្រជាជនដើម្បីទទួលបានសំណូកជាប្រាក់កាក់។ | យើងដឹងថាមានរោងចក្រកាត់ដេរមួយចំនួនបានបដិសេធមិនព្រមផ្តល់ការងារឱ្យអ្នកមានផ្ទុកមេរោគអេដស៍។ |
| **កំណត់គោលដៅ** | មន្ទីរពេទ្យ និង គ្លីនិកធំបំផុតចំនួន ៦ នៅក្នុងខេត្តធំចំនួន ៦។ | ជ្រើសរើសសំណាកតំណាងឱ្យរោងចក្រកាត់ដេរទាំងឡាយ។ |
| **ជ្រើសរើសអ្នកស្ម័គ្រចិត្ត** | ជ្រើសរើសអ្នកដែលអាចសួកប្រាក់ដល់បុគ្គលិកមន្ទីរពេទ្យ និង គ្លីនិក។ | សហការជាមួយក្រុមអ្នកសម្របសម្រួលការងារអេដស៍ ដូចជា បណ្តាញអ្នកផ្ទុកមេរោគអេដស៍កម្ពុជា ដែលហៅកាត់ថា CPN+ ដើម្បីស្វែងរកអ្នកដែលផ្ទុកមេរោគអេដស៍ ហើយមានបំណងដាក់ពាក្យសុំការងារនៅរោងចក្រកាត់ដេរមួយចំនួនដែលបានកំណត់។ |
| **ធ្វើសកម្មភាព** | អ្នកស្ម័គ្រចិត្តនឹងសូកបុគ្គលិកមន្ទីរពេទ្យ និង គ្លីនិក។ សូមកត់ត្រាដោយប្រុងប្រយ័ត្ននូវរាល់ការឆ្លើយតប។ ឱ្យអ្នកស្ម័គ្រចិត្តយើងថតចំលងការសន្ទនាជាមួយបុគ្គលិកទាំងនោះ ដោយប្រើឧបករណ៍ថតសំឡេង ឬ រូបភាពជាសម្ងាត់។ | អ្នកស្ម័គ្រចិត្តនោះនឹងដាក់ពាក្យសុំការងារធ្វើ ហើយត្រូវតែប្រាប់ពីស្ថានភាពមេរោគអេដស៍របស់ខ្លួន ដោយឱ្យអ្នកស្ម័គ្រចិត្តយើងថតចម្លងការសន្ទនាជាមួយបុគ្គលិកទាំងនោះ ដោយប្រើឧបករណ៍ថតសំឡេង ឬ រូបភាពជាសម្ងាត់។ |
| **ឡើងតុលាការ** | ប្រើប្រាស់ច្បាប់ស្តីពី ការបង្ការ និង ការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជម្ងឺអេដស៍ មាត្រាទី៣១ និង មាត្រាទី៣៣ ប្តឹងបុគ្គលិកមន្ទីរពេទ្យ និង គ្លីនិកនោះ។ អ្នករំលោភបែបនេះនឹងត្រូវពិន័យជាប្រាក់ពី ៥០.០០០ (ប្រាំម៉ឺន)រៀល ដល់ ២០០.០០០ (ម្ភៃម៉ឺន)រៀល និង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ)ខែ ដល់ ៦ (ប្រាំមួយ)ខែ ហើយចំពោះមន្ត្រីរាជការត្រូវទទួលទណ្ឌកម្មបន្ថែមផ្នែករដ្ឋបាល។ | ប្រើប្រាស់ច្បាប់ស្តីពី ការបង្ការ និង ការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជម្ងឺអេដស៍ មាត្រាទី ៣៦ ប្តឹងបុគ្គលិករោងចក្រកាត់ដេររូបនោះ។ អ្នករំលោភបែបនេះនឹងត្រូវពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន)រៀល ដល់ ១.០០០.០០០ (មួយលាន)រៀល និង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ)ខែ ដល់ ៦ (ប្រាំមួយ)ខែ។ ករណីពុំរាងចាល ត្រូវផ្តន្ទាទោសទ្វេជាពីរ ហើយចំពោះមន្ត្រីរាជការត្រូវទទួលទណ្ឌកម្មបន្ថែមផ្នែករដ្ឋបាល។ |

# ការរៀបចំផែនការយុទ្ធសាស្ត្រច្បាប់

ដើម្បីរៀបចំយុទ្ធសាស្ត្រផ្នែកច្បាប់មួយសម្រាប់ពង្រឹងនូវកិច្ចខិតខំប្រឹងប្រែងតស៊ូមតិរបស់យើង យើងត្រូវឆ្លើយនូវសំណួរមួយចំនួនដូចខាងក្រោម ដោយមានជំនួយពីមេធាវីដែលបានទទួលការបណ្តុះបណ្តាលច្បាស់លាស់ :

### តើកូនក្តីរបស់យើងចង់ឡើងតុលាការដែរឬទេ ?

តើកូនក្តីរបស់យើងបានរៀបចំជាស្រេចដើម្បីចាត់វិធានការផ្លូវច្បាប់ហើយឬនៅ ? តើយើងបានរៀបចំសព្វគ្រប់ហើយឬនៅដើម្បីពួកគេទាមទារយុត្តិធម៌នៅក្នុងតុលាការ ?

### តើករណីនោះសមស្របសម្រាប់គោលបំណងរួមនៃការតស៊ូមតិរបស់យើងដែរឬទេ ?

ជាការសំខាន់ត្រូវឱ្យមានតុល្យភាពរវាងគោលបំណងរួមនៃយុទ្ធនាការតស៊ូមតិផ្នែកច្បាប់ដែលជោគជ័យរបស់យើងជាមួយនឹងការព្រួយបារម្ភរបស់យើងទៅលើកូនក្តី ។ ក្នុងករណីដែលតម្រូវការរបស់កូនក្តីមិនស្របទៅនឹងគោលបំណងរួមនៃការតស៊ូមតិរបស់យើង យើងគួរតែបញ្ជូនករណីនេះទៅអង្គការផ្សេងៗដែលពាក់ព័ន្ធលើករណីនេះ ។

### តើយើងគួរនាំក្តីនេះឡើងតុលាការដែរឬទេ ?

មុនពេលឡើងតុលាការ យើងត្រូវឱ្យប្រាកដថាយើងមានជំនាញ និង បទពិសោធន៍ និង ឯកសារចាំបាច់គ្រប់គ្រាន់ដើម្បីមានលទ្ធភាពខ្ពស់ក្នុងការផ្តល់ជោគជ័យដល់កូនក្តីរបស់យើង ។

### តើមានច្បាប់ណាមួយដែលអាចដោះស្រាយការរំលោភនេះដោយផ្ទាល់ឬទេ ?

ធ្វើការស្រាវជ្រាវថាតើច្បាប់បច្ចុប្បន្នអាចអនុវត្តបានសម្រាប់ស្ថានភាពរបស់កូនក្តីយើងដែរឬទេ។ ស្រាវជ្រាវរដ្ឋធម្មនុញ្ញ និង ច្បាប់អន្តរជាតិនានា ដើម្បីកំណត់ថាតើមានច្បាប់ផ្សេងៗទៀតអាចអនុវត្តបានសម្រាប់ស្ថានភាពរបស់កូនក្តីយើងដែរឬទេ? ត្រូវមានការច្នៃប្រឌិតខ្ពស់ ! ពិចារណាថាតើសិទ្ធិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញដូចជា សិទ្ធិទទួលបានការថែទាំសុខភាព សុវត្ថិភាពផ្ទាល់ខ្លួន ការអប់រំ និង សិទ្ធិក្នុងការបញ្ចេញមតិអាចអនុវត្តបានដែរឬទេ?



តើកូនក្តីរបស់យើងចង់ឡើងតុលាការដែរឬទេ ?

- **បាទ ចាស៎** → តើករណីនោះសមស្របសម្រាប់គោលបំណងរួមនៃការតស៊ូមតិរបស់យើងដែរឬទេ ?
  - **បាទ ចាស៎** → តើយើងគួរតែឡើងតុលាការ ដើម្បីដោះស្រាយករណីនេះដែរឬទេ ?
  - **ទេ** → បញ្ជូនករណីនេះទៅអង្គការផ្សេងៗទៀតដែលសមស្រប។
- **ទេ** → កំណត់សេវាកម្មណាដែលសមស្របសម្រាប់ពួកគេ ហើយបើអាចធ្វើទៅបាន សូមផ្តល់យោបល់ដល់ពួកគេ។

**បាទ ចាស់**

**តើមានច្បាប់ណាមួយដែលអាចដោះស្រាយការរំលោភដោយផ្ទាល់ឬទេ ?**

**បាទ ចាស់** សហការជាមួយមេធាវីដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវដើម្បីធ្វើការជាមួយកូនក្តីក្នុងការរៀបចំពាក្យបណ្តឹង។ បើសិនជាអាចធ្វើទៅបាន ត្រូវច្របាច់បណ្តឹងតវ៉ាស្រដៀងគ្នាទាំងឡាយបញ្ចូលគ្នា ហើយប្រើ**ច្បាប់ដែលកំពុងមានក្នុងការឡើងតុលាការ !**

**ទេ** សហការជាមួយមេធាវីដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវដើម្បីធ្វើការជាមួយកូនក្តីក្នុងការរៀបចំពាក្យប្តឹងពួកគេ។ ប្រសិនបើអាចធ្វើទៅបាន ត្រូវច្របាច់បញ្ចូលបណ្តឹងតវ៉ាទាំងឡាយបញ្ចូលគ្នាស្រដៀងគ្នាច្រើន ហើយប្រើ**ច្បាប់រដ្ឋធម្មនុញ្ញ ឬ ច្បាប់អន្តរជាតិក្នុងការឡើងតុលាការ !**

**ទេ** ធ្វើករណីនេះឱ្យកាន់តែរឹងមាំដោយធ្វើការសាកល្បងលើករណីប្រមូលភស្តុតាង ឬ សហការជាមួយអង្គការដែលមានជំនាញផ្សេងៗទៀត។




បើទោះបីជាមិនមានច្បាប់ណាមួយដែលអាចអនុវត្តបានដោយផ្ទាល់សម្រាប់ស្ថានភាពកូនក្តីរបស់យើងក៏ដោយ យើងអាចយកជម្រើសឡើងតុលាការ ដើម្បីទាក់ទាញការចាប់អារម្មណ៍ ដើម្បីឱ្យមាន**ការកែលំអច្បាប់**។

# ធ្វើយ៉ាងដូចម្ដេចប្រសិនបើគ្មានច្បាប់ ?

ជួនកាលមិនមានច្បាប់ណាមួយដែលយើងអាចប្រើប្រាស់សម្រាប់ដោះស្រាយបញ្ហាកូនក្ដីរបស់យើងដោយផ្ទាល់បានឡើយ។ ក្នុងករណីនេះ យើងចាំបាច់ត្រូវប្រើប្រព័ន្ធច្បាប់ដើម្បីបង្ហាញនូវតម្រូវការច្បាប់ថ្មីមួយ។ ខាងក្រោមនេះគឺជារបៀបប្រើប្រាស់មួយចំនួន :

## ប្រើប្រាស់**ច្បាប់ដែលមានស្រាប់**

ប្រសិនបើមិនមានច្បាប់ណាមួយដែលអាចប្រើបានសម្រាប់ដោះស្រាយបញ្ហារបស់កូនក្ដីយើងដោយផ្ទាល់បានទេនោះ យើងអាចប្រើច្បាប់ស្រដៀងគ្នានេះ ដើម្បីការពារសិទ្ធិរបស់កូនក្ដីយើងនៅក្នុងតុលាការ។ ឧទាហរណ៍ ប្រទេសកម្ពុជាមិនទាន់មានច្បាប់ប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ តែយើងអាចកាត់ទោសភាគីប្ដី ឬ ប្រពន្ធនោះបានដោយប្រើច្បាប់បង្ករបួសស្នាមដល់អ្នកដទៃ ដែលកំពុងមានជាធរមានដើម្បីកាត់សេចក្ដីអំពើហិង្សាក្នុងគ្រួសារនោះ។

## ប្រើប្រាស់**ច្បាប់អន្តរជាតិ**

ចូរចងចាំថា ប្រទេសកម្ពុជាក៏ត្រូវអនុវត្តតាមច្បាប់អន្តរជាតិដែរ។ ដូចនេះយើងអាចប្ដឹងជនល្មើស ប៉ូលិស ឬ រដ្ឋាភិបាល ពីបទមិនអនុវត្តតាមច្បាប់អន្តរជាតិ ឬ សន្ធិសញ្ញាអន្តរជាតិណាមួយក៏បាន។

## បញ្ចុះបញ្ចូល**អង្គការអន្តរជាតិ**

អង្គការអន្តរជាតិអាចជួយនាំយកពាក្យបណ្ដឹងរបស់យើងឡើងតុលាការអន្តរជាតិ ឬ អាចបង្កើតសាលាក្ដីអន្តរជាតិ ដើម្បីកាត់ក្ដីណាមួយដែលសមស្រប។

### ការតស៊ូមតិនៅ**កម្ពុជា**

**តើអ្វីទៅជាសាលាក្ដី ?**

សាលាក្ដី គឺជាតុលាការមួយ ដែលមានសិទ្ធិធ្វើការសម្រេចលើរឿងក្ដីជាក់លាក់មួយចំនួន។ បច្ចុប្បន្ននេះ សាលាក្ដីអន្តរជាតិត្រូវបានបង្កើតឡើងនៅក្នុងប្រទេសរ៉្វាន់ដា និង នៅអតីតយូហ្គោស្លាវី ដើម្បីកាត់ទោសជនប្រព្រឹត្តិបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង បទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ក្នុងពេលសង្គ្រាម។ បច្ចុប្បន្ននេះ អង្គការសហប្រជាជាតិបាននឹងកំពុងពិភាក្សាពីលទ្ធភាពបង្កើតសាលាក្ដីបែបនេះ នៅក្នុងប្រទេសស៊ីរ៉ាលេអូន ទីម័រខាងកើត និង នៅក្នុងប្រទេសកម្ពុជា។

## ប្រើប្រាស់**រដ្ឋធម្មនុញ្ញ**

ច្បាប់រដ្ឋធម្មនុញ្ញគឺជាច្បាប់កំពូលនៃប្រទេស។ រដ្ឋធម្មនុញ្ញការពារសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋដូចជា សិទ្ធិទទួលបានការថែទាំសុខភាព សុវត្ថិភាពផ្ទាល់ខ្លួន ការអប់រំ និង សិទ្ធិក្នុងការបញ្ចេញមតិ។ល។ ដូចនេះយើងអាចប្ដឹងជនល្មើស ប៉ូលិស ឬ រដ្ឋាភិបាល ពីបទរំលោភរដ្ឋធម្មនុញ្ញលើករណីណាមួយ។

## ប្រើប្រាស់**ក្រុមប្រឹក្សាធម្មនុញ្ញ**

ប្រសិនបើទទួលបានការគាំទ្រមួយភាគដប់ពីសមាជិករដ្ឋសភាជាតិ មួយភាគបួនពីសមាជិកព្រឹទ្ធសភា ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី តុលាការ ឬ ពីព្រះមហាក្សត្រ យើងអាចសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញធ្វើការពិនិត្យឡើងវិញលើធម្មនុញ្ញភាពនៃច្បាប់ដែលកំពុងមាន។

## រៀបចំ**តុលាការក្លែងក្លាយ** (Mock Court)

យើងអាចអញ្ជើញអ្នកជំនាញច្បាប់ដើម្បីធ្វើការជាមួយសិស្ស ជនរងគ្រោះ ឬ អ្នកដទៃទៀត ដើម្បីបង្កើតតុលាការក្លែងក្លាយមួយ។ នៅក្នុងតុលាការក្លែងក្លាយនេះ យើងអាចផ្ដល់ករណីមួយចំនួនដែលមិនអាចនាំយកទៅតុលាការពិតប្រាកដបាន។ ជំរុញឱ្យអ្នកធ្វើសេចក្ដីសម្រេចឱ្យទទួលស្គាល់បញ្ហាតាមរយៈការផ្សព្វផ្សាយតុលាការក្លែងក្លាយរបស់យើងនេះជាសាធារណៈតាមប្រព័ន្ធផ្សព្វផ្សាយ។

## **ការរៀបចំឯកសារ** និង **ការគាំទ្រ**

ប្រមូលភស្តុតាងលើការរំលោភ និង ត្រូវផ្សព្វផ្សាយលទ្ធផលនៃការស្រាវជ្រាវនេះដើម្បីជំរុញឱ្យមានការដឹងឮជាសាធារណៈពីភាពអយុត្តិធម៌។

# ការបង្កើតតុលាការសាធារណមតិ

ទោះបីជាការឡើងតុលាការគឺជាផ្នែកមួយដ៏សំខាន់សម្រាប់ដំណើរការតស៊ូមតិក៏ដោយ តែវានៅមិនទាន់គ្រប់គ្រាន់នៅឡើយទេ។ ការសម្រេចរបស់ចៅក្រមតែងតែមិនដូចទៅនឹងអ្វីដែលយើងសង្ឃឹមទុកទាំងស្រុងឡើយដែលជាឧបសគ្គដល់ការឈានទៅសម្រេចបាននូវគោលបំណងរួមនៃការតស៊ូមតិរបស់យើង។ នៅពេលណាមានករណីបែបនេះកើតឡើង យើងចាំបាច់ត្រូវរៀបចំឱ្យមានការបង្កើតតុលាការសាធារណមតិ។ តាមរយៈតុលាការសាធារណមតិ យើងអាចបង្ហាញករណីរបស់យើងដោយផ្ទាល់ជូនសាធារណជន ដើម្បីឱ្យពួកគេកៀបសង្កត់អ្នកធ្វើសេចក្តីសម្រេចឱ្យចាត់វិធានការ។ ខាងក្រោមនេះគឺជាមធ្យោបាយមួយចំនួនសម្រាប់រៀបចំតុលាការសាធារណមតិ ៖

## ប្រមូលភស្តុតាង



### ថតវីដេអូ

ថតវីដេអូដើម្បីយកភស្តុតាងនៃការរំលោភបំពាននានា និង ផលប៉ះពាល់ទៅលើជនរងគ្រោះ



### ថតរូបភាព

ថតរូបភាពដើម្បីបង្ហាញពីបញ្ហា ឬ ផលប៉ះពាល់នៃបញ្ហាដែលបានកើតឡើងនោះ



### សម្ភាសន៍

កត់ត្រារាល់ការសន្ទនាជាមួយសមាជិកសហគមន៍ដែលរងគ្រោះ និង ការសន្ទនានានាជាមួយជនរងគ្រោះ និង អ្នកប្រព្រឹត្តបទល្មើស



### ការរៀបចំឯកសារ

ប្រមូលភស្តុតាងជាលាយលក្ខណ៍អក្សរ ឬ ឯកសារច្បាប់នានាពាក់ព័ន្ធនឹងការរំលោភបំពាន

ម្នាក់ក្នុងចំណោមស្ត្រីចំណាស់៨នាក់...
ម្នាក់ក្នុងចំណោមស្ត្រី៤នាក់...
ម្នាក់ក្នុងចំណោមកុមារ៣នាក់...
៣នាក់ក្នុងចំណោមបុរស៥នាក់...
៥នាក់ក្នុងចំណោមក្មេងស្រីជំទង់៦នាក់...

### ស្ថិតិ

ប្រមូលស្ថិតិទាំងឡាយអំពីការរំលោភបំពាន ពីប្រភពជាច្រើន រួមទាំងបញ្ជីសំណួរដែលយើងបានសួរកូនក្តីផងដែរ។



## ការតស៊ូមតិនៅ កម្ពុជា

នៅក្នុងឆ្នាំ១៩៩៥ អង្គការ Global Witness ដែលជាអង្គការអន្តរជាតិមួយឃ្លាំមើលបទល្មើសព្រៃឈើពិភពលោក បានកត់ត្រានូវប្រតិបត្តិការកាប់ព្រៃឈើដោយខុសច្បាប់ដែលមានតម្លៃរាប់លានដុល្លារអាមេរិករវាងក្រុមហ៊ុនកាប់ឈើថៃជាមួយកងកម្លាំងខ្មែរក្រហម។ ក្រោយពីបានផ្សព្វផ្សាយភស្តុតាងបទល្មើសខាងលើ អង្គការនេះបានប្រើច្បាប់អន្តរជាតិបង្ខំឱ្យរដ្ឋាភិបាលថៃបិទច្រកព្រំដែនរបស់ខ្លួនដើម្បីទប់ស្កាត់ការរកស៊ីកាប់ឈើខុសច្បាប់នេះ។ យុទ្ធនាការនេះក៏បានចូលរួមធ្វើឱ្យចលនាខ្មែរក្រហមដួលរលំផងដែរ ដោយសារពួកគេអត់មានមូលនិធិគាំទ្រចលនារបស់ខ្លួនបន្តទៀត។

លោកអ្នកអាចទទួលបានព័ត៌មានបន្ថែម តាមរយៈវេបសាយ ៖

**http://www.globalwitness.org**

# ការបង្កើតតុលាការសាធារណមតិ

## នាំយកភស្តុតាងដើម្បីបង្ហាញដល់សាធារណជន



### បោះពុម្ពផ្សាយ

ផ្សព្វផ្សាយភស្តុតាងនៅតាមកាសែតទស្សនាវដ្តី ឬ ព្រឹត្តិប័ត្រនានា។ ប្រសិនបើរដ្ឋាភិបាលមានការពាក់ព័ន្ធដែរនោះ ត្រូវធ្វើទំនាក់ទំនងជាមួយអ្នកកាសែតអន្តរជាតិ ព្រោះពួកគេមានសុវត្ថិភាពផ្ទាល់ខ្លួនប្រសើរជាងអ្នកកាសែតក្នុងស្រុក។



### ផលិតជាខ្សែភាពយន្ត

ផលិតខ្សែភាពយន្តមួយដែលបង្ហាញពីការរំលោភបំពាន និង សាច់រឿងរបស់ជនរងគ្រោះ ហើយដាក់បញ្ចាំងខ្សែវីដេអូនេះនៅតាមសារមន្ទីរ សាលារៀន តាមអ៊ីនធឺណេត ឬ តាមរថយន្ត។ល។



### កសាងសារមន្ទីរ ឬ អនុស្សាវរីយ៍

ភ្ញៀវទេសចរមានចំណាប់អារម្មណ៍ជាពិសេសទៅលើសារមន្ទីរ និង អនុស្សាវរីយ៍នានា ហើយពួកគេនឹងនាំយកនូវព័ត៌មាន និង គំនិតទាំងនោះទៅកាន់ប្រទេសកំណើតរបស់គេវិញ។



### ផ្សព្វផ្សាយតាមរយៈកម្មវិធីវិទ្យុ

វិទ្យុគឺជាមធ្យោបាយផ្សព្វផ្សាយទូទាំងប្រទេសមួយដែលមានតម្លៃសមស្រប ជាពិសេសប្រជាពលរដ្ឋដែលរស់នៅតាមទីជនបទអាចស្តាប់ពួកម្មវិធីផ្សព្វផ្សាយនេះបានដែរ។



### បញ្ចូលសាធារណជន

ធ្វើពិធីប្រកួតប្រជែងគូររូបភាពដើម្បីជំរុញឱ្យមហាជនបង្ហាញនូវរូបភាពតាមពិសោធន៏ទាំងឡាយរបស់ពួកគេ។ តាំងរូបភាពរបស់ពួកគេមានអមដោយតួលេខ ឬ ស្ថិតិដើម្បីពង្រឹងសាររបស់យើង។



### ផ្សព្វផ្សាយស្ថិតិ

បញ្ចូលស្ថិតិអំពីអំពើហិង្សាចូលទៅក្នុងយុទ្ធនាការតាមប្រព័ន្ធផ្សព្វផ្សាយរបស់យើង។

**រូបភាព :** យោងតាមការស្រាវជ្រាវថ្មីៗនេះបានឱ្យដឹងថា ១/៤នៃស្ត្រី នៅក្នុងប្រទេសកម្ពុជា ត្រូវបានទទួលរងនូវការរំលោភបំពានដោយអំពើហិង្សាក្នុងគ្រួសារ។ គណៈ-កម្មាធិការស្ត្រីកម្ពុជា (CAMBOW) បានបញ្ចូលស្ថិតិនេះនៅក្នុងផ្លាកសញ្ញារបស់ពួកគេ។



### សរសេរសៀវភៅ

ការសរសេរសៀវភៅអំពីអំពើហិង្សា ផ្តល់ឱ្យយើងនូវឱកាសមួយដើម្បីប្រាប់រឿងរ៉ាវយ៉ាងពេញលេញ។



### ការបង្កើតវេបសាយ

ដោយសារវេបសាយមានអត្ថបទចម្រុះ និង រូបភាពប្រកបដោយការទាក់ទាញ វាជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងទំនាក់ទំនងជាមួយអង្គគោលដៅបានយ៉ាងទូលាយ។



### ការតស៊ូមតិនៅ **កម្ពុជា**

តាមរយៈការវិភាគយ៉ាងលំអិតទៅលើឯកសារ រូបថត អត្ថបទនៃសម្ភាសន៏ជាមួយបុគ្គលមួយចំនួន និង នីតិវេជ្ជសាស្ត្រ មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលហៅកាត់ថា DC-CAM បានបង្កើតឱ្យមានករណីផ្នែកច្បាប់មួយដ៏គួរឱ្យជឿទុកចិត្តបានសម្រាប់សាលាក្តីអន្តរជាតិកាត់ទោសខ្មែរក្រហម។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្ហាញភស្តុតាងទាំងនេះជាសាធារណៈតាមរយៈមធ្យោបានជាច្រើន ដូចជាការតាំងពិព័រណ៏រូបភាពនៅសារមន្ទីរទួលស្លែង តាមរយៈទស្សនាវដ្តីវេបសាយ ការផ្សព្វផ្សាយតាមវិទ្យុ និង តាមរយៈសៀវភៅមួយក្បាលទៀតដែលនឹងបោះពុម្ពក្នុងពេលឆាប់ៗខាងមុខនេះដែលនិយាយអំពីរឿងរ៉ាវផ្ទាល់ខ្លួនរបស់អ្នកនិពន្ធ និង បទសម្ភាសន៏មួយចំនួនទៀតពាក់ព័ន្ធទៅនឹងការឈឺចាប់នៃការរស់នៅក្រោមរបបខ្មែរក្រហម។
លោកអ្នកអាចទទួលបានព័ត៌មានបន្ថែម តាមរយៈវេបសាយ :
**http://www.dcccam.org**

# ក្រមសីលធម៌




នៅក្នុងកម្រងអត្ថបទសម្រាប់អ្នកជំនាញតស៊ូមតិនេះ យើងបានបង្ហាញនូវបទពិសោធន៍ល្អៗដែលអ្នកតស៊ូមតិនានានៅជុំវិញពិភពលោកបានប្រើប្រាស់។ យើងបានដឹងហើយថាអ្នកតស៊ូមតិតែងតែធ្វើការនៅកន្លែងណាដែលមានច្បាប់មិនសូវច្បាស់លាស់ ហើយការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យនៅក្មេងខ្ចី។ ការគោរពតាមច្បាប់ដើម្បីអនុម័តនូវនីតិកម្មសំខាន់ៗ អាចប្រើពេល ថាមពល និង ធនធាន។ ទោះជាការសូកមន្ត្រី អាចបង្កើនល្បឿននៃការអនុម័តច្បាប់ក៏ដោយ ក៏យើងពុំត្រូវធ្វើឡើយ។ បើសិនជាយើងមិនបានធ្វើការតស៊ូមតិជាចំហដោយស្មោះត្រង់ ស្របច្បាប់ មានតម្លាភាព និង ប្រកបដោយក្រមសីលធម៌ទេនោះ យើងនឹងធ្វើឱ្យអ្នកតស៊ូមតិដទៃទៀតដែលអនុវត្តតាមយើងជួបការលំបាកជាក់ជាមិនខាន។

**ប្រសិនបើកិច្ចខិតខំប្រឹងប្រែងលើការតស៊ូមតិរបស់យើងមិនបានធ្វើឱ្យជីវិតរស់នៅរបស់ប្រជាពលរដ្ឋបានល្អប្រសើរពិតប្រាកដទេនោះ យើងត្រូវតែបញ្ឈប់សកម្មភាពរបស់យើងភ្លាម ហើយធ្វើការពិចារណា និង ចោទសួរលើរាល់សកម្មភាពនានារបស់យើងឡើងវិញ។**

# ការឃ្លាំមើលតុលាការ

ជាធម្មតាប្រព័ន្ធតុលាការមិនតែងតែមានដំណើរការក្នុងរូបភាពបើកចំហ ស្មោះត្រង់ ស្របច្បាប់ មានតម្លាភាព និង ប្រកបដោយក្រមសីលធម៌នោះទេ។ ដូចនេះយើងមានវិធីសាស្ត្រមួយដើម្បីធ្វើឱ្យប្រព័ន្ធតុលាការមានដំណើរការត្រឹមត្រូវ គឺត្រូវធ្វើការតាមដានដំណើរការកាត់ក្ដីរបស់តុលាការ។ យើងអាចឃ្លាំមើលតុលាការដោយបញ្ជូនអ្នកតំណាងដែលទទួលបានការបណ្ដុះបណ្ដាលឱ្យចូលរួមសវនាការកាត់ក្ដី និង កត់ត្រានូវការវិនិច្ឆ័យ ការសម្រេច និង វិធានការរបស់តុលាការ។ ក្នុងករណីចាំបាច់ យើងអាចទាក់ទាញអ្នកក្នុងស្រុក និង អន្តរជាតិ ឱ្យចាប់អារម្មណ៍លើឥរិយាបថមិនប្រក្រតីរបស់ចៅក្រម ព្រះរាជអាជ្ញា ឬ ក្រឡាបញ្ជីតុលាការ។ "ការតាមដានតុលាការ" នឹងអាចរារាំងឥរិយាបថមិនស្របច្បាប់របស់អ្នកទាំងនោះ ហើយអាចជំរុញឱ្យតុលាការមានដំណើរការមិនលំអៀង។

# សន្និដ្ឋាន

ប្រព័ន្ធច្បាប់គឺជាឧបករណ៍ដ៏ល្អមួយក្នុងចំណោមឧបករណ៍ល្អទាំងឡាយ ដើម្បីប្រយុទ្ធប្រឆាំងនឹងការសង្កត់សង្កិនជិះជាន់ ភាពក្រីក្រ និង ភាពអយុត្តិធម៌។ ដូច្នេះ ការយល់ដឹងលើប្រព័ន្ធច្បាប់ គឺជាជំនាញមួយសំខាន់បំផុតដែលមិនអាចខ្វះបានក្នុងយុទ្ធនាការតស៊ូមតិ។ ចាប់ផ្ដើមពីការធ្វើពង្រាងច្បាប់រហូតដល់ឡើងតុលាការ គឺយើងអាចប្រើប្រព័ន្ធច្បាប់ដើម្បីធ្វើឱ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋបានល្អប្រសើរ និង ដើម្បីសម្រេចបានគោលបំណងរួមនៃការតស៊ូមតិរបស់យើង។ អ្នកអាចចាប់ផ្ដើមយុទ្ធនាការតស៊ូមតិរបស់អ្នកបានហើយដោយប្រើប្រាស់នូវជំនាញ និង ចំណេះដឹងដែលអ្នកបានរៀនសូត្រពីសៀវភៅនេះ រួមទាំងសៀវភៅ៤ក្បាលផ្សេងទៀតនៃកម្រងអត្ថបទសម្រាប់អ្នកជំនាញតស៊ូមតិនេះ។



"អយុត្តិធម៌នៅកន្លែងណាមួយ

គឺជាការគំរាមកំហែងដល់យុត្តិធម៌នៅគ្រប់ទីកន្លែង "។

Martin Luther King

# សទ្ទានុក្រម

**គ្រប់គ្រងរដ្ឋបាល** (ADMINISTER)

ចាត់ចែង ដឹកនាំ ត្រួតពិនិត្យ ឬ ដោះស្រាយបញ្ហា ឬ បញ្ហាច្បាប់ ។

**អាជ្ញាកណ្ដាល** (ARBITRATION)

គឺជាដំណើរការដែលមានមនុស្សពីរនាក់ ឬ ពីរក្រុមធ្វើការតែងតាំងមនុស្សមិនលំអៀងមួយរូប ឬ មួយក្រុមឱ្យជួយដោះស្រាយជម្លោះ ។

**រដ្ឋប្បវេណី** (CIVIL)

ពាក់ព័ន្ធទៅនឹងប្រជាពលរដ្ឋ និង ទំនាក់ទំនងរវាងគ្នា ឬ ជាមួយអង្គការរដ្ឋ ។

**សំណង** (COMPENSATE)

ការផ្ដល់នូវអ្វីមួយដូចជា ប្រាក់កាស ឬ ពេលវេលា ជាការទូទាត់ចំពោះសកម្មភាពបំពានណាមួយ ។

**ឧក្រិដ្ឋកម្ម** (CRIMINAL)

ការប្រព្រឹត្តិខុសច្បាប់ ។

**ការរើសអើង** (DISCRIMINATION)

ការរាប់អានមនុស្សម្នាក់ ឬ មួយក្រុម ខុសពីមនុស្សម្នាក់ ឬ មនុស្សមួយក្រុមទៀត ។

**យុត្តាធិការ** (JURISDICTION)

ជាអំណាចធ្វើសេចក្ដីសម្រេចស្របច្បាប់ ។

**តុលាការក្លែងក្លាយ** (MOCK COURT)

ជាតុលាការមួយត្រូវបានបង្កើតឡើងក្លែងក្លាយ ហើយធ្វើដូចជាដំណើរការនៃតុលាការពិត ។

**ជនល្មើស** (PERPETRATOR)

ជាបុគ្គលដែលបានបំពាន ឬ រំលោភច្បាប់ ។

**ចោទប្រកាន់** (PROSECUTE)

បន្តដំណើរការនៃការជំនុំជម្រះក្ដីរឿងព្រហ្មទណ្ឌ ។

**សាលាក្ដី** (TRIBUNAL)

តុលាការដែលត្រូវបានបង្កើតឡើងសម្រាប់កាត់ក្ដីលើករណីជាក់លាក់ណាមួយ ។

**សិទ្ធិ** (RIGHTS)

ជាសិទ្ធិដែលបានផ្ដល់ឱ្យប្រជាពលរដ្ឋ ។




## ឯកសារយោង

សម្រាប់ព័ត៌មានបន្ថែមអំពីប្រធានបទទាំងនេះ សូមអាន :

វេបសាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល :
http://www.arbitrationcouncil.org

វេបសាយរបស់អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា :
http://www.cdpcambodia.org

រដ្ឋធម្មនុញ្ញកម្ពុជា :
htpp://www.cambodia.gov.kh/unisql1/egov/khmer/organ.constitution.html

សេចក្ដីផ្ដើមអំពីដំណើរការតុលាការកម្ពុជា : លោក កុយ នាម, អង្គការមូលនិធិអាស៊ី (១៩៩៨)

ការគិតពិចារណាយ៉ាងច្បាស់លាស់ផ្នែកច្បាប់ : នីតិបញ្ញត្តិ - សៀវភៅសិក្សាភាគទី ២

លោក បណ្ឌិត វិលហិម ទ្រេប៊ិរ, លោក អានជ្រេ បេម និង ហ៊ួត សុទ្ធារី - វិទ្យាស្ថានខ្មែរសម្រាប់លទ្ធិប្រជាធិប្បតេយ្យ (២០០៤)
http://www.bigpond.com.kh/users/kid

## សេចក្ដីថ្លែងអំណរគុណជាពិសេស

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវាគ្មិនទាំងអស់ដែលបានមកចូលរួមនៅក្នុងការបណ្ដុះបណ្ដាលវគ្គទី ៥ របស់យើងខ្ញុំ ។

លោក ឆាំង យុ, លោក ហ្វ្រែង ហ្វេលហ្ស៊ែរ, លោក ណែល ហ្វ្រែងគ្លីន, លោក អែនឌ្រូ ហ្គូហ្វ៍, លោក ប្រ៊ូស ឡាស្គី, លោក បញ្ញាវុធ ឡុង, លោកស្រី ឡូរ៉ា ម៉ាក់ហ្គ្រូវី, លោក កុយ នាម, លោក រ៉ូប៊ឺត អុបប៊ែនដូហ្វ៍, លោក សុក សំអឿន, លោក អាង ឧត្ដម, លោក យ៉ុង ផានិត, អ្នកស្រី អែម សុឃីម, កញ្ញា នូ ភារី, អ្នកស្រី ណុប សារិនស្រីរ័ត្ន, លោក ស៊ីម សុរិយា, លោក ម៉ាឃើស ហាដធ៍ខេ និង លោក ស្កត់ វ៉ឺដិន ។

Youk Chhang, Frank Felser, Neil Franklin, Andrew Goffe, Bruce Lasky, Panhavuth Long, Laura McGrew, Koy Neam, Robert Oberndorf, Sok Sam Oeun, Ang Udom, Yung Phanit, Em Sokhym, Nou Pheary, Nop Sarin Srey Roth, Sim Sorya, Marcus Hardtke, and Scott Worden

# ព័ត៌មានកូនក្តី

**កំណត់សម្គាល់ :**
ប្រសិនបើយើងជួបប្រទះនូវសំណួរដែលកូនក្តីមិនអាចឆ្លើយបាន សូមសរសេរថា "**នាពេលនេះ កូនក្តីមិនអាចឆ្លើយ**" ក្នុងទម្រង់ព័តិមានកូនក្តី។

## ព័ត៌មានជាមូលដ្ឋាន

លេខករណី :

កាលបរិច្ឆេទនៃការចាប់ផ្តើមបើករឿងក្តី : ______________
ថ្ងៃ ខែ ឆ្នាំ

កាលបរិច្ឆេទនៃការកត់ត្រាព័តិមានខាងក្រោម : ______________
ថ្ងៃ ខែ ឆ្នាំ

បុគ្គលិកដែលកំពុងបំពេញទម្រង់នេះ :

តើម្ចាស់ករណីធ្លាប់គិតអំពីការផ្តល់ប្រឹក្សាផ្នែកច្បាប់ទាក់ទងនឹងរឿងក្តីនេះដែរឬទេក្នុងពេលកន្លងមក ? **បាន/ចាស់** **ទេ**

ប្រសិនបើបាទ/ចាស់ តើនៅពេលណា ហើយអ្នកណាជាអ្នកផ្តល់ប្រឹក្សានេះ ?

តើយើងធ្លាប់បានចាត់វិធានការលើបញ្ហាណាមួយជាមួយកូនក្តីរូបនេះដែរឬទេកាលពីមុន ? **បាន/ចាស់** **ទេ**

ប្រសិនបើបាទ/ចាស់ នៅពេលណា ?

តើជាប្រភេទបញ្ហាអ្វី ?

# ព័ត៌មានកូនក្តី

ឈ្មោះ ______________________ ______________________

គោត្តនាម នាម

ថ្ងៃខែឆ្នាំកំណើត និង ទីកន្លែងកំណើត :

ភេទ :

អាសយដ្ឋានបច្ចុប្បន្ន :

ចាប់តាំងពី :

ចំនួនឆ្នាំ :

លេខទូរស័ព្ទទំនាក់ទំនង :

សាច់ញាតិជិតជាងគេ/អ្នកដែលអាចទាក់ទងពេលបន្ទាន់ :

ត្រូវជា :

ចំនួនកូន :

សមាជិកគ្រួសារដែលស្ថិតនៅក្នុងបន្ទុក និង ទំនាក់ទំនងជាមួយជនជាប់ចោទ :

១. ត្រូវជា :

២. ត្រូវជា :

៣. ត្រូវជា :

មុខរបរ :

(សូមឱ្យកូនក្តីរៀបរាប់ដោយសង្ខេបពីប្រវត្តិការងាររបស់គេ)

និយោជក :

ចាប់តាំងពី :

ប្រាក់ចំណូលរបស់កូនក្តី :

ប្រាក់ចំណូលគ្រួសាររបស់កូនក្តី :

កំរិតវប្បធម៌ :

(សូមឱ្យកូនក្តីបកស្រាយដោយសង្ខេបពីប្រវត្តិនៃការអប់រំ ដូចជា ថ្នាក់មធ្យមសិក្សាដែលបានចូលរៀន ឬ ចំនួនឆ្នាំដែលបានចូលរៀន។ សូមសួរកូនក្តីបន្ថែមពីវគ្គបណ្តុះបណ្តាល ឬ វិញ្ញាបនបត្រមួយចំនួនដែលគាត់បានទទួលកន្លងមក)

## សាវតារនៃបញ្ហា

ព័ត៌មានលំអិតអំពីបញ្ហា ៖

ឯកសារដែលកូនក្តីនាំយកមកជាមួយពេលធ្វើសម្ភាសន៍ ៖
(រូបថត ទិន្នានុប្បវត្តិ និង កំណត់ត្រាជាផ្លូវការផ្សេងៗទៀត ។ល ។)

១. មានភ្ជាប់ឯកសារថតចំលង ? **បាទ/ចាស៎** **ទេ**

២. មានភ្ជាប់ឯកសារថតចំលង ? **បាទ/ចាស៎** **ទេ**

៣. មានភ្ជាប់ឯកសារថតចំលង ? **បាទ/ចាស៎** **ទេ**

ឈ្មោះ និង អាសយដ្ឋានរបស់សាក្សី ឬ គូប្រឆាំងដែលមានសក្ខានុពលរបស់កូនក្តី ប្រសិនបើករណីនេះឡើងទៅតុលាការ ៖

១. ត្រូវជា ៖

២. ត្រូវជា ៖

៣. ត្រូវជា ៖

ឈ្មោះរបស់អ្នកផ្សេងទៀតដែលបានពាក់ព័ន្ធនឹងបញ្ហានេះ ព្រមទាំងការបរិយាយលំអិតថាតើតួនាទីរបស់ពួកគេទាក់ទងនឹងកូនក្តីដោយរបៀបណា ៖

១. ត្រូវជា ៖

២. ត្រូវជា ៖

៣. ត្រូវជា ៖

តើកូនក្តីបាននិយាយពីបញ្ហានេះជាមួយនគរបាល ឬ មន្ត្រីរដ្ឋបាលមូលដ្ឋានដែរឬទេ ? **បាទ/ចាស៎** **ទេ**

ប្រសិនបើបាទ/ចាស៎ តើនិយាយជាមួយអ្នកណា ?

នៅពេលណា ?

តើមានការកត់ត្រាជាលាយលក្ខណ៍អក្សរពីពាក្យបណ្តឹងនោះដែរឬទេ ? **បាទ/ចាស៎** **ទេ**

តើកូនក្តីបានទទួលការថែទាំសុខភាពឬទេ ពាក់ព័ន្ធនឹងបញ្ហានេះ ? **បាទ/ចាស៎** **ទេ**

**វត្ថុតាងអាចមើលឃើញ**

- ☐ ជាំ ដាច់រលាត់ ឬ របួស
- ☐ រូបថត
- ☐ អាវុធជាតិផ្ទុះ
- ☐ សម្លៀកបំពាក់
- ☐ ______
- ☐ ______
- ☐ ______

## វិធានការដែលត្រូវអនុវត្ត

ក្នុងការសហការជាមួយកូនក្តី សូមរៀបរាប់នៅក្នុងជំហានបន្តបន្ទាប់ដែលយើងនឹងត្រូវធ្វើសម្រាប់កូនក្តី។ សូមបញ្ចូលនូវគោលបំណងនានារបស់កូនក្តី និង កំណត់ធនធាននានាដែលកូនក្តីមានដែលនឹងជួយឱ្យសម្រេចគោលបំណងទាំងនេះ។

ឯកសារដែលកូនក្តីត្រូវតែមាន :

១.

២.

៣.

តើអ្វីដែលត្រូវធ្វើដើម្បីដោះស្រាយបញ្ហានេះ ?

សកម្មភាពដែលយើងអនុវត្តមុនពេលប្រជុំលើកក្រោយ :

កាលបរិច្ឆេទ និង ទីកន្លែងប្រជុំលើកក្រោយជាមួយកូនក្តី :

តើមានការកត់ត្រាអំពីពេលវេលា និង កាលបរិច្ឆេទសម្រាប់ការប្រជុំលើកក្រោយជាមួយកូនក្តីរួចហើយឬនៅ ? **បាទ/ចាស៎** **ទេ**

សង្ខេប និង/ឬ ចំណាប់អារម្មណ៍នៃការធ្វើសម្ភាសន៍ :

ហត្ថលេខាបុគ្គលិក

ថ្ងៃ ខែ ឆ្នាំ